**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០៧៤/១៥ ក.អ.ជ.ប្រក

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំមមី ព.ស.២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា គ.ស ២០១៥

# ប្រកាស

## ស្តីពី

## ការកែសម្រួលសមាសភាពក្រុមការងារយេនឌ័ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងប្រកាសលេខ ០០៦៩/០៩ ក.អ.ជ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមការងារយេនឌ័រ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១÷** កែសម្រួលសមាសភាពក្រុមការងារយេនឌ័ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដូចខាងក្រោម÷

១. លោកជំទាវ **ម៉ាត់ ម៉ារ៉ា** រដ្ឋលេខាធិការ ប្រធាន

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

| | | | |
|---|---|---|---|
| ២. លោកជំទាវ | **ឆេព បូរ៉ាមីន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. លោកស្រី | **ឡាច សារ៉ម៉ន** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | អនុប្រធាន |
| ៤. លោក | **ឆូច សំណាង** | អគ្គនាយករងបច្ចេកទេស | សមាជិក |
| ៥. លោកស្រី | **ឆូច គីមពៅ** | អធិការរងនៃអគ្គាធិការដ្ឋាន | សមាជិកា |
| ៦. លោក | **ឈាត សំណាង** | ប្រធាននា.បណ្តុះបណ្តាល និងស្រាវជ្រាវ | សមាជិក |
| ៧. លោកស្រី | **ខៀវ មាលតី** | អនុប្រធាននា.ផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិកា |
| ៨. កញ្ញា | **ឡាយ ធីរៈបុត្រ** | អនុប្រធាននា.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិកា |
| ៩. លោក | **នង សុវណ្ណារស្មី** | អនុប្រធាននា.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |
| ១០. លោក | **ទីន ហ្វេសោល** | អនុប្រធាននា.អភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ១១. លោក | **ឆួន ពេជ្រនិមិត្ត** | អនុប្រធាននា.ផ្គត់ផ្គង់ទឹកជនបទ | សមាជិក |
| ១២. លោក | **ឯក សុខីណា** | អនុប្រធាននា.ផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. លោកស្រី | **ឈាង សុខណា** | អនុប្រធាននា.ជនជាតិភាគតិច | សមាជិកា |
| ១៤. លោកស្រី | **ចាន់ ច្រិប** | អនុប្រធាននា.សវនកម្មផ្ទៃក្នុង | សមាជិកា |
| ១៥. កញ្ញា | **សំ សុភី** | អនុប្រធាននា.ថែទាំសុខភាពជនបទ | សមាជិកា |
| ១៦. លោក | **អ៊ុំ ម៉ានីរ៉ា** | អនុប្រធាននា.ផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១៧. លោក | **លន់ សាយរតន** | ប្រធានការិ.អប់រំសុខភាពសហគមន៍ | សមាជិក |
| ១៨. លោក | **ឆូច ស៊ីផាត** | ប្រធានការិ.បណ្តុះបណ្តាល និងស្រាវជ្រាវ | សមាជិក |
| ១៩. លោកស្រី | **ទ៉ូយ គីមសែន** | អនុប្រធានការិ.ផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិកា |
| ២០. លោកស្រី | **ហាក្ស សុគីន** | អនុប្រធានការិ.ផែនការ និងស្ថិតិ | សមាជិកា |
| ២១.កញ្ញា | **ច័ន្ទ សុរិយា** | អនុប្រធានការិ.កិច្ចការទូទៅ | សមាជិកា |
| ២២.កញ្ញា | **ហោ បូឡា** | មន្ត្រី នា.ផ្លូវលំជនបទ | សមាជិកា |
| ២៣.លោក | **ឃុត បញ្ញា** | មន្ត្រី នា.ផ្លូវលំជនបទ | សមាជិក |
| ២៤.លោក | **ស៊ិច ទាសនា** | មន្ត្រី នា.ផ្គត់ផ្គង់ទឹកជនបទ | សមាជិក |
| ២៥.លោកស្រី | **ថាង ឌីណា** | មន្ត្រី នា.ថែទាំសុខភាពជនបទ | សមាជិកា |
| ២៦. លោក | **អេង ឌីម៉ង់** | មន្ត្រី នា.សវនកម្មផ្ទៃក្នុង | សមាជិក |

**ប្រការ ២**÷ ក្រុមការងារយេនឌ័រក្រសួងអភិវឌ្ឍន៍ជនបទមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំកម្មវិធី និងគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាសមធម៌យេនឌ័រ និងគិតគូរពិចារណាក្នុងការបញ្ជ្រាបយេនឌ័រ
- បង្កើតបណ្តាញយេនឌ័រពីថ្នាក់ជាតិ ដល់មូលដ្ឋាន
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលធនធានមនុស្សផ្នែកយេនឌ័រ របស់ក្រសួងអភិវឌ្ឍន៍ជនបទទាំងថ្នាក់ជាតិ ទាំងថ្នាក់រាជធានី ខេត្ត សម្រាប់លើកកម្ពស់សមធម៌យេនឌ័រមានលក្ខណៈជាប្រព័ន្ធ ទៅក្នុងផែនការអភិវឌ្ឍន៍ជនបទ

- កសាងផែនការសកម្មភាព ដែលពាក់ព័ន្ធការងារប្រចាំខែ និងប្រចាំឆ្នាំ
- បញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងកម្មវិធីនានារបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- សម្របសម្រួល សហការ ស្វែងរកការគាំទ្រថវិកា និងបច្ចេកទេសពីបណ្តាស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីលើកកម្ពស់ការងារយេនឌ័រ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- សម្របសម្រួល ផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មានជាមួយក្រុមការងារយេនឌ័រតាមក្រសួងនានា និងអង្គការមិនមែនរដ្ឋាភិបាល
- សម្របសម្រួលដល់កិច្ចការនារីនៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ
- ចាត់ចែង និងរៀបចំប្រារព្ធទិវាអន្តរជាតិនារី ៨ មីនា ជារៀងរាល់ឆ្នាំ តាមការចាត់តាំងរបស់ក្រសួង
- សម្របសម្រួលជាមួយថ្នាក់ដឹកនាំក្រសួងក្នុងការតែងតាំង ចាត់តាំងឱ្យមានលក្ខណៈយេនឌ័រនៅក្នុងគម្រោងនានា
- ត្រួតពិនិត្យ និងវាយតម្លៃនូវរាល់សកម្មភាពដែលបានអនុវត្ត ពាក់ព័ន្ធនឹងការងារយេនឌ័រ និងរៀបចំសូចនាករ
- អនុវត្តភារកិច្ចផ្សេងទៀតដែលក្រសួងប្រគល់ជូន។

**ប្រការ ៣ ÷** រាល់សេចក្តីសម្រេចណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ ÷** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន គ្រប់ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងសាមីជន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

រដ្ឋមន្ត្រី

ជា សុផារ៉ា

__កន្លែងទទួល÷__
- ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី
- ក្រសួងកិច្ចការនារី
- ស្ថាប័ន អង្គការពាក់ព័ន្ធ
  *"ដើម្បីជូនជ្រាប"*
- ដូចមានចែងក្នុងប្រការ ១ និងប្រការ ៤
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

Download